16 ឧសភា 2017



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

លេខ០១..សណន

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែឧសភាឆ្នាំ២០១៧

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងវិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព សម្រាប់ដំណើការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ៤ នៅថ្ងៃអាទិត្យ ទី០៤ ខែ មិថុនា ឆ្នាំ ២០១៧

គិតមកដល់ពេលបច្ចុប្បន្ននេះ ការរៀបចំដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៤ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលមួយដ៏ហានដោយពុំមានសភាពការណ៍អ្វីធំដុំកើតឡើង ជះឥទ្ធិពលប៉ះពាល់គួរកត់សម្គាល់ឡើយ ក្នុងនោះបានរៀបចំការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ប្រកបដោយសុវត្ថិភាព និងបានប្រកាសលទ្ធផលជាផ្លូវការ ដែលមានប្រជាជនសរុប ស្មើនឹង ៨១.៣៨ % នៃចំនួនប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត បានចុះឈ្មោះបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានដំណើរការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងបានបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅតាមគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) រួចហើយ ដែលក្នុងនោះមានគណបក្សនយោបាយចំនួន១២ ចូលរួមប្រកួតប្រជែង និងកំពុងបន្តដំណើរការកិច្ចការជាច្រើនទៀតតាមប្រតិទិន ដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតតាមការគ្រោងទុក ។

អាស្រ័យហេតុនេះ ដើម្បីធានាឲ្យកាន់តែល្អប្រសើរនូវសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៤ ឆ្នាំ២០១៧ នាពេលខាងមុខនេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សូមធ្វើការណែនាំដល់គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ សហការជាមួយ គ.ជ.ប ឬនិងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដូចខាងក្រោម ៖

១. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ដែលជាក្បាលម៉ាស៊ីនដឹកនាំយន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតអចិន្ត្រៃយ៍នៅហ្នឹងកន្លែងត្រូវបន្តយកចិត្តទុកដាក់ដឹកនាំការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេស ដឹកនាំជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឲ្យក្លាយជាយុទ្ធនាការមួយព្រមៗគ្នាគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស ក្នុងគោលបំណងកៀរគរគ្រប់សមាសភាពទាំងអស់ក្នុងសង្គមចូលរួមឲ្យបានសកម្ម ។

២. ត្រូវយកចិត្តទុកដាក់ខិតខំស្រាវជ្រាវ ស៊ើបអង្កេតឲ្យបានហ្មត់ចត់រាល់បទល្មើសនានា ដែលកើតឡើង ជាពិសេស បទល្មើសព្រហ្មទណ្ឌដែលមានការចោទប្រកាន់ពាក់ព័ន្ធផ្នែកនយោបាយ និងឧបទ្ទវហេតុនានាដែលពាក់ព័ន្ធដល់បរិយាកាសនយោបាយ ដូចជាការគំរាមកំហែង ការបំភិតបំភ័យ ឬការទម្លាក់ស្លាក ផ្តួលរំលំស្លាក ការលាបពណ៌ផ្សេងៗលើស្លាកគណបក្សនានា ដើម្បីស្វែងរកចាប់ខ្លួនជនប្រព្រឹត្តបទល្មើសយកទៅផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៣. ត្រូវចាត់វិធានការសកម្មក្នុងការប្រមែប្រមូលព័ត៌មានពីគ្រប់ប្រភព ដើម្បីពិចារណា វិភាគវាយតម្លៃសន្និដ្ឋានរាល់ហេតុការណ៍ដែលកើតឡើង ពិសេសយកចិត្តទុកដាក់រាល់ទិន្នន័យទាំងអស់ ដែលពាក់ព័ន្ធដល់សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៃកិច្ចដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ។ ត្រូវយកចិត្តទុកដាក់ក្តាប់ជាប់រាល់បាតុភាពទំនាស់ផ្សេងៗ ក្នុងប្រជាពលរដ្ឋ ការប្រមូលផ្តុំតវ៉ា ឬការធ្វើបាតុកម្ម កូដកម្មនានារបស់កម្មករ និងប្រជាពលរដ្ឋ ដោយត្រូវខិតខំសម្របសម្រួលដោះស្រាយ មិនទុកឲ្យមានផលប៉ះពាល់ដល់ការបោះឆ្នោតនាថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ ។

៤. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវបន្តសហការចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពជូនគ្រប់តំណាងឬភ្នាក់ងារ និងបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋដែលត្រូវចូលរួមក្នុងដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ឲ្យបានមធ្យ័តបំផុតតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

៥. ត្រូវបន្តយកចិត្តទុកដាក់សហការរៀបចំ និងចាត់វិធានការការពារសន្តិសុខ សុវត្ថិភាព នៅគ្រប់គោលដៅសំខាន់ៗជាអាទិ៍ ទីកន្លែងជួបជុំ ទីស្នាក់ការគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឧបករណ៍មធ្យោបាយ សម្ភារឃោសនា ទីតាំងរក្សាទុក ឬក្បួនដឹកជញ្ជូនសម្ភារ និងឯកសារបោះឆ្នោតរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៦. ត្រូវយកចិត្តទុកដាក់ផ្តល់សេវាសន្តិសុខដោយស្មើភាពគ្នា ជូនគ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ជាពិសេស ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវផ្តោតសំខាន់លើការបែងចែកកម្លាំងការពារគ្រប់ក្បួនឃោសនាបោះឆ្នោត ការពារនៅជុំវិញបរិវេណ នៃអង្គពិធីឃោសនាដោយធានារក្សាឲ្យបានសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរណ៍ ព្រមទាំងបរិយាកាសនយោបាយល្អ គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ឬការបង្កចលាចល ឬការអុកឡុកវឹកវរផ្សេងៗ ។

៧. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវសហការឲ្យបានល្អជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៧ ដែលជាថ្ងៃស្ងប់ស្ងៀម ឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតរបស់ គ.ជ.ប ។ ភ្នាក់ងារសន្តិសុខបោះឆ្នោតសហការជាមួយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតធានាឲ្យបានដាច់ខាតសន្តិសុខការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីដែលបានកំណត់ដោយ គ.ជ.ប ។

៨. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំឲ្យមានក្រុមប្រចាំការអចិន្ត្រៃយ៍ ដើម្បីទទួលព័ត៌មាន និងដោះស្រាយព័ត៌មានពាក់ព័ន្ធដល់ការបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ទន្ទឹមនោះត្រូវរៀបចំឲ្យមានក្រុមប្រតិកម្មរហ័ស ដើម្បីឆ្លើយតបចំពោះបាតុភាព ឬឧបទ្ទវហេតុផ្សេងៗ ជៀសវាងការកេងចំណេញខាងផ្នែកនយោបាយ ឬក្នុងគោលបំណងបំផ្លាញការបោះឆ្នោត

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចាត់ចែងអនុវត្តឲ្យបានហ្មត់ចត់នូវផែនការអន្តរស្ថាប័នលេខ០០៩ ផក/១៦ ចុះថ្ងៃទី ១៩-០៥-២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្ដីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ និងត្រូវចាត់ចែងរៀបចំឲ្យមានការប្រជុំរៀនសូត្រ ណែនាំ ដល់ភ្នាក់ងារសន្តិសុខបោះឆ្នោត និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធឲ្យយល់ដឹងអំពីច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោត ព្រមទាំងឲ្យអនុវត្តបានត្រឹមត្រូវ ដើម្បីធានាបរិយាកាសបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានការគំរាមកំហែងដែលអាចទទួលយកបាន ។

១០. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ត្រូវធានារបាយការណ៍ឲ្យបានទៀងទាត់ជារៀងរាល់ថ្ងៃចាប់ពីពេលនេះតទៅ និងមួយថ្ងៃ ០២ ដង ( ព្រឹកម៉ោង ០៨.០០ និងរសៀលម៉ោង ១៦.០០ ) ចាប់ពីថ្ងៃចាប់ផ្ដើមយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ការបោះឆ្នោតបានចប់សព្វគ្រប់ជាស្ថាពរ លើកលែងករណីបន្ទាន់ជះឥទ្ធិពលដល់ផ្នែកនយោបាយត្រូវរាយការណ៍ជាវិសាមញ្ញ ជូនមកលេខាធិការដ្ឋាននៃ គ.ស.អ ដើម្បីមានវិធានការដោះស្រាយសមស្រប និងទាន់ពេលវេលា ។

ទទួលបានសេចក្ដីណែនាំនេះ សូមគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត សមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព ។

ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

សម្ដេចក្រឡាហោម ស ខេង

<u>ចម្លងជូន ៖</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- គ្រប់សមាជិករបស់ គ.ស.អ
- លេខាធិការដ្ឋាននៃ គ.ស.អ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ